## 581* ព្រះបន្ទូលដ៏រស់

(អ. 801)




២. មានតែព្រះបន្ទូលយើងអាចស្គាល់ព្រះអង្គ
បើកសម្ដែងសេចក្ដីពិត ដល់គ្រប់មនុស្ស
មានតែព្រះបន្ទូលយើង ស្ដាប់សូរសៀងទ្រង់
ហើយសម្ដែងអង្គទ្រង់ តាមបទគម្ពីរនោះ ។

៣. ទ្រង់ជាការប្រែសភាពនៃរូបអង្គព្រះ
បង្ហាញពីរូបអង្គទ្រង់ តាមព្រះបន្ទូល
សម្ដែងឲ្យយើងបានឃើញទ្រង់ យ៉ាងជាក់ច្បាស់
ឲ្យខ្ញុំឃើញព្រះអង្គ ក្នុងព្រះគម្ពីរទាំងមូល ។

៤. ទ្រង់ជាវិញ្ញាណជីវិត ជាព្រះបន្ទូល
ឲ្យខ្ញុំប៉ះពាល់ព្រះអង្គ ដោយប្រើវិញ្ញាណ
ក៏ជាព្រះវិញ្ញាណនៅក្នុងព្រះបន្ទូល
ទទួលភាពបរិបូរពោរពេញអង្គប្រាណ ។

៥. នៅក្នុងព្រះអង្គខ្ញុំ ប្រកបយ៉ាងស្នាលស្និទ្ធ
គ្រប់ពេលខ្ញុំអធិដ្ឋាន អានព្រះបន្ទូល
ឲ្យបានចិញ្ចឹមដោយព្រះបន្ទូលជីវិត
ភាពបរិបូរបំពេញគ្រប់តម្រូវការ ។

៦. ទ្រង់បង្រៀនឲ្យខ្ញុំចេះហ្វឹកហាត់វិញ្ញាណ
ទទួលភាពបរិបូរ ពោរពេញក្នុងខ្ញុំ
អានអធិដ្ឋានឲ្យបានប៉ះពាល់ព្រះអង្គ
ជាម៉ាណាចិញ្ចឹមខ្ញុំជារៀងរាល់ថ្ងៃ ។

# ការអានអធិដ្ឋាន

យហ .៦:៦៣ គឺជាព្រះវិញ្ញាណទេ ដែលឱ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះគឺជាវិញ្ញាណ និងជីវិតវិញ។

## ព្រះបន្ទូលរបស់ព្រះជាអាហាររបស់យើង

ព្រះគម្ពីរបរិសុទ្ធ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយយើងក៏រស់នៅដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រមកដែរ។ ព្រះគម្ពីរបានប្រាប់យើងទៀតថា ព្រះបន្ទូលរបស់ព្រះគឺជាអាហាររបស់យើង។ នៅក្នុងគម្ពីរយ៉ូហាន ៦:៣៥ ព្រះអម្ចាស់យេស៊ូបានមានបន្ទូលថា៖ "ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ អ្នកនោះនឹងមិនឃ្លានទៀតឡើយ។

ទោះជាយ៉ាងណាក៏ដោយ បើគ្រាន់តែមានអាហារ ដែលបានរៀបចំជាស្រេចនៅលើតុ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ រឿងដ៏សំខាន់បំផុតគឺអ្នកត្រូវមកបរិភោគ ប៉ុន្តែបើអ្នកមិនបរិភោគទេ អ្នកប្រាកដជាមិនទទួលបានការចិញ្ចឹមឡើយ។ គ្រិស្តានត្រឹមត្រូវ ដែលមានជីវិតរស់រវើកនិងរឹងមាំ ត្រូវរៀនធ្វើរឿងមួយ គឺបរិភោគព្រះបន្ទូលនៃជីវិត។

## ទទួលយកព្រះបន្ទូលដោយសេចក្ដីអធិដ្ឋានគ្រប់យ៉ាង

យើងត្រូវការអានអធិដ្ឋានព្រះបន្ទូលមិនមែនគ្រាន់តែអានប៉ុណ្ណោះទេ។ ពីសតវត្សរ៍មួយទៅសតវត្សរ៍មួយ ពួកអ្នកដែលស្រឡាញ់ដល់ព្រះអង្គ បូករួមទាំងអ្នករៀនព្រះគម្ពីរជាច្រើនផង បានអនុវត្តនូវការអានអធិដ្ឋានយ៉ាងដូច្នេះ ទោះបីជាពួកគេពុំទាន់មានពាក្យថា *អានអធិដ្ឋាន* ក៏ដោយ។ នៅសម័យនោះអ្នកខ្លះបានបង្ហាញថា យើងត្រូវការអានព្រះគម្ពីរ ដោយសេចក្ដីអធិដ្ឋានយ៉ាងពេញលេញ។ ការអានព្រះគម្ពីរ ដោយសេចក្ដីអធិដ្ឋានយ៉ាងពេញលេញ គឺជាការអានអធិដ្ឋាននោះឯង។

ឥឡូវឧទាហរណ៍ថា បងប្អូនប្រុសទាំងពីរនាក់ដដែល គាត់ចូលមកឯព្រះបន្ទូលដោយនិយាយដូច្នេះថា៖" ឱព្រះអម្ចាស់អើយ កាលដើមដំបូងឡើយ! កាលដើមដំបូងឡើយមានព្រះបន្ទូល អាម៉ែន! ហាលេលូយ៉ា ដ្បិតកាលដើមដំបូងឡើយ ឱព្រះអម្ចាស់អើយ គឺមានព្រះបន្ទូល! ហាលេលូយ៉ា គឺមានព្រះបន្ទូល! ហើយព្រះនបន្ទូលនៅជាមួយនឹងព្រះ! ឱព្រះអង្គអើយ! ហើយព្រះបន្ទូលនោះឯងជាព្រះ! "។ នៅពេលដែលយើងហ្វឹកហាត់ប្រើវិញ្ញាណ ប៉ះពាល់ព្រះគម្ពីរតាមមធ្យោបាយដ៏រស់ដូច្នេះ ប្រហែលជាយើងមិនសូវយល់ប៉ុន្មានទេ ប៉ុន្តែយើងត្រូវបានបំពេញដោយព្រះវិញ្ញាណ ព្រមទាំងទទួលបានជីវិតផ្គត់ផ្គង់ថែមទៀតផង។

ការអានអធិដ្ឋាន គឺជារឿងដ៏អស្ចារ្យ ប៉ុន្តែយើងត្រូវអធិដ្ឋានដូច្នេះថា៖ "ព្រះអម្ចាស់អើយ សូមជម្រសម្អាតផ្នែកខាងក្នុងទូលបង្គំផង។ ឱព្រះអម្ចាស់អើយ សូមទ្រង់មានសេរីភាពនៅក្នុងទូលបង្គំ" ។ ជាការពិត ការអានអធិដ្ឋានមិនមែនដើម្បីជួយឱ្យយើងទទួលបានចំណេះទេ ប៉ុន្តែគឺដើម្បីនាំគ្រប់ទាំងអស់របស់ព្រះអម្ចាស់ ចូលមកក្នុងយើង។ ដូច្នេះ យើងត្រូវការអនុញ្ញាតឱ្យគ្រប់ទាំងអស់របស់ព្រះគ្រិស្ត មានសេរីភាពនៅក្នុងយើង ដ្បិតការនេះជួយឱ្យយើងមានការកិនរំលាយ និងការរលាយជ្រាបចូលខាងវិញ្ញាណ នូវអ្វីដែលយើងបានអានអធិដ្ឋាន។